ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
គ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា(គ.អ.ឆ.ក) សូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែកក្កដា ឆ្នាំ២០២១ **ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស.) និងជាប្រធាន គ.អ.ឆ.ក.** បានដឹកនាំកិច្ចប្រជុំ គ.អ.ឆ.ក. តាមប្រព័ន្ធ Zoom ដោយមានការចូលរួមពី **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.អ.ឆ.ក. **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធាន គ.អ.ឆ.ក. ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងជាសមាជិក គ.អ.ឆ.ក. ឯកឧត្តម **សោម ពិសិដ្ឋ** អភិបាលនៃគណៈអភិបាលខេត្តកែប និងជាសមាជិក គ.អ.ឆ.ក. តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិក គ.អ.ឆ.ក. ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួង ដ.ន.ស. ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន សរុបប្រមាណ ៦៣ រូប។

កិច្ចប្រជុំបានផ្តោតលើ **១.** វឌ្ឍនភាពនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន ៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ ការរៀបចំផែនការចុះត្រួតពិនិត្យ វាយតម្លៃ និងប្រគល់-ទទួល ការបង្ហោះដ្រូនថតរូបភាពពីលើអាកាសនៅខេត្តព្រះសីហនុសម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង **២.** វឌ្ឍនភាពនៃការស្ថាបនាផ្លូវតភ្ជាប់ពីវិថី២ធ្នូ ចំណុចឆ្នេរសុខា ទៅផ្លូវលេខ ៥០២ ចំណុចឆ្នេរអូរឈើទាល ស្ថិតនៅពាយ័ព្យ **៣.** វឌ្ឍនភាពនៃការស្ថាបនាស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយទី១ ស្ថានីយទី២ និងលើកទិសដៅស្ថាបនាស្ថានីយទី៣ **៤.** គម្រោងប្លង់អភិវឌ្ឍរមណីយដ្ឋានឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប និង **៥.** ស្ថានភាពថវិការបស់ គ.អ.ឆ.ក.។

កិច្ចប្រជុំទទួលបានលទ្ធផលដូចខាងក្រោម÷

**១. វឌ្ឍនភាពនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន ៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ**

គិតចាប់ពីថ្ងៃបើកសម្ពោធការដ្ឋាននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតមកដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន ៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ មានរយៈពេល ៥៥៩ថ្ងៃ និងសម្រេចលទ្ធផលដូចខាងក្រោម÷

- ការងារកម្រាលផ្លូវបេតុង, ការងារដំឡើងលូទឹកភ្លៀងនិងទឹកកខ្វក់, ការងារដំឡើងលូរណប,ការងារ អ៊ុតកៅស៊ូ, ការងាររៀបខឿនចិញ្ចើមផ្លូវ, ការងារចិញ្ចើមផ្លូវសាធារណៈ, ការងារគំនូសចរាចរណ៍, ការងារដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវ, ការងារដំឡើងផ្លាកសញ្ញាចរាចរណ៍, ការងារដាំដើមឈើ និង ការងារស្ថាបនាផ្ទាំងអក្សរ"**ខ្មែរធ្វើបាន**"សម្រេចបាន ១០០%
- ការងារដំឡើងភ្លើងសញ្ញាចរាចរណ៍ សម្រេចបាន ៨៥%
- ការងារបំពាក់កាមេរ៉ាសុវត្ថិភាពសម្រេចបាន ៦៧% នៅសល់ការងារភ្ជាប់បណ្តាញអគ្គិសនីនិង បណ្តាញខ្សែអុបទិកជាមួយកាមេរ៉ា
- ការងារស្ថាបនាបន្ទប់ទឹកសាធារណៈចំនួន ៩ ទីតាំង សម្រេចបាន ៩៥% ក្នុងនោះមាន ៥ ទីតាំង សម្រេចបាន ១០០%
- ការងារស្ថាបនារង្វង់មូលនិងបដិមាទាំង ៣ ក្នុងនោះរង្វង់មូលនិងបដិមាចំនួន ២ បានបញ្ចប់ការ ដំឡើងរួចរាល់ គឺរង្វង់មូលព្រះសិរៈ និងរង្វង់មូលសីហរាជមុខបី ដោយឡែករង្វង់មូលព្រះថោង នាងនាគ សម្រេចបាន ៩០%។

ក្នុងដំណើរការអនុវត្តគម្រោងខាងលើ គ.អ.ធ.ក. បានចូលរួមកែលម្អឆ្នេរ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ បន្ថែមចាំបាច់ដូចខាងក្រោម÷

- ស្ថាបនាផ្លូវអាទិភាពថ្មីចំនួន ៣ខ្សែ ដែលមាន ២ គន្លងរថយន្ត និង ២ គន្លងគោចក្រយានយន្ត រួមមាន ផ្លូវលេខ ៨១៨៨ ប្រវែង ៨០៩ម៉ែត្រ ផ្លូវលេខ ៨០១ ប្រវែង ៩៥៦ម៉ែត្រ និងផ្លូវលេខ ៨០៦ ប្រវែង ៧២៨ម៉ែត្រ។ ដូចនេះ ខ្សែផ្លូវសរុបចំនួន ៣៧ ខ្សែ ប្រវែងសរុប ៨៤ ០៦៥ ម៉ែត្រ មានផ្ទៃ ក្រឡាសរុប ១ ៤៧០ ៥១១ម៉ែត្រការ៉េ រួមមានមហាវិថីចំនួន ៣ ខ្សែ វិថីចំនួន ១៧ ខ្សែ និងអនុវិថី ចំនួន ១៧ ខ្សែ
- ស្ថាបនានិងជួសជុលពង្រីកស្ពានថ្មីចំនួន ៨ ទីតាំង មានប្រវែងសរុប ២៧២ ម៉ែត្រ រួមមាន ស្ពាន សែនត្រជាក់ចិត្ត ប្រវែង ៤៥ ម៉ែត្រ, ស្ពានព្រែកទប់ ប្រវែង ៣០ ម៉ែត្រ, ស្ពានព្រះសិរៈ ប្រវែង ៥០ ម៉ែត្រ ស្ពានព្រះថោង ប្រវែង ៣០ ម៉ែត្រ, ស្ពានទី ១ វិថីសែនជ័យ ប្រវែង ១២ ម៉ែត្រ, ស្ពានទី ២ វិថីសែនជ័យ ប្រវែង ១៥ ម៉ែត្រ, ស្ពានទី ៣ វិថីសែនជ័យ ប្រវែង ៤៥ ម៉ែត្រ និងស្ពានសែនជ័យ ប្រវែង ៤៥ ម៉ែត្រ
- រៀបចំកែលម្អឆ្នេរសមុទ្រប្រវែង ១៨ ៨៧៤ ម៉ែត្រ ចាប់ពីឆ្នេរសុខាដល់ឆ្នេររាមឱ្យមាន សោភណភាពឡើងវិញដោយបានបើកឆ្នេរសមុទ្រចំនួន ៣ ទីតាំង មានប្រវែងសរុប ៣ ១៣៤ ម៉ែត្រ រួមមានឆ្នេរពយតាម្លង ប្រវែង ១ ០៣៤ ម៉ែត្រ, ឆ្នេរពយអូរព្រើតាល ប្រវែង ២៥០ ម៉ែត្រ និងឆ្នេរពយជិតាវម៉ោ ប្រវែង ១ ៨៥០ ម៉ែត្រ
- រៈបើសំណង់បណ្តោះអាសន្នគ្រប់ប្រភេទតាមបណ្តោយឆ្នេរសមុទ្រ ក្នុងនោះឆ្នេរអូរព្រើតាល ចំនួន ១២៦ ទីតាំង, ឆ្នេរអូរព្រះ ចំនួន ១៥៦ ទីតាំង និងឆ្នេរលំហែកាយចំនួន ១២ ទីតាំង សរុប

២៩៤ ទីតាំង ដោយជំនួសមកវិញនូវការស្ថាបនាតូបទេសចរណ៍ ផ្លូវថ្មើរជើងប្របឆ្នេរ លម្អសាធារណៈ បន្ទប់ទឹកអនាម័យ កន្លែងអង្គុយកម្សាន្តទស្សនាសមុទ្រនិងទេសភាពក្រុង ការដាំដើមឈើបន្ថែមដែលជួយដល់បរិស្ថានឆ្នេរកាន់តែមានភាពល្អប្រសើរ

- ស្តារប្រឡាយ អូរធម្មជាតិ ចំនួន ៦ ខ្សែ ស្ថិតក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានប្រវែងសរុប ២៧ ១១៧ ម៉ែត្រ សម្រេចបាន ២០ ៥៤៤ ម៉ែត្រ និងមានប្រជាពលរដ្ឋរងផលប៉ះពាល់សរុបចំនួន ៧៣៣ គ្រួសារ ក្នុងនោះប៉ះពាល់ទាំងស្រុង ២២៣ គ្រួសារ និងប៉ះពាល់ដោយផ្នែក ៥១០ គ្រួសារ
- សម្របសម្រួលជាមួយប្រជាពលរដ្ឋក្នុងការពង្រីកផ្លូវស្របតាមប្លង់សុរិយោដី ដោយប្រជាពលរដ្ឋស្ម័គ្រចិត្តរុះរើសំណង់ដែលសាងសង់លើដីសាធារណៈ ដោយមិនទាមទារដោះស្រាយផលប៉ះពាល់ ហើយអាជ្ញាធរនិងប្រជាពលរដ្ឋបានចូលរួមថែរក្សាបរិស្ថានក្រោយពេលផ្លូវត្រូវបានស្ថាបនារួច។

ទន្ទឹមនេះ គ.អ.ឆ.ក. នឹងបន្តអនុវត្តការងារដូចខាងក្រោម÷

- ចុះត្រួតពិនិត្យ វាយតម្លៃ និងប្រគល់-ទទួលហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន ៣៤ ខ្សែ ក្នុងខេត្តព្រះសីហនុ
- ចុះបង្ហោះដ្រូនថតរូបភាពពីលើអាកាសនៅខេត្តព្រះសីហនុ សម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង
- រៀបចំកម្មវិធី Street View នៅក្រុងព្រះសីហនុ ដោយមានរូបភាពប្រៀបធៀបឆ្នាំ ២០១៤ ឆ្នាំ ២០១៩ និងឆ្នាំ ២០២១។

**២. វឌ្ឍនភាពនៃការស្ថាបនាផ្លូវតភ្ជាប់ពីវិថី២ធ្នូ ចំណុចឆ្នេរសុខា ទៅផ្លូវលេខ ៥០២ ចំណុចឆ្នេរអូរឈើទាល ស្ថិតនៅឃុំពាម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**

អនុវត្តតាមលិខិតលេខ ២៦ សជណ.ជប ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា បានរៀបចំកែលម្អឆ្នេរសមុទ្រពាម ពីវិថី២ធ្នូ ចំណុចឆ្នេរសុខា ទៅផ្លូវលេខ ៥០២ ចំណុចឆ្នេរអូរឈើទាល ដោយស្ថាបនាផ្លូវប្រវែង ១ ០៣៤ ម៉ែត្រ ទទឹង ១០,២៥ ម៉ែត្រ ចាក់បេតុងកម្រាស់ ២៥ សង់ទីម៉ែត្រ អ៊ុតកៅស៊ូបេទិមកម្រាស់ ៧ សង់ទីម៉ែត្រ ចិញ្ចើមផ្លូវសងខាងក្រាលកម្រាលថ្មក្រានីត បំពាក់បង្គោលភ្លើងបំភ្លឺអមសងខាងផ្លូវ និងមានសួនច្បារនៅចំណុចប្រសព្វជាមួយវិថី២ធ្នូ។ បច្ចុប្បន្ន សម្រេចលទ្ធផលបានប្រមាណ ៩៥% ក្នុងនោះ ការងារកម្រាលផ្លូវបេតុង សម្រេចបាន ១០០%, ការងារដំឡើងភ្លើង សម្រេចបាន ១០០%, ការងាររៀបខឿនថ្មក្រានីត ចិញ្ចើមផ្លូវថ្មក្រានីត សម្រេចបានប្រមាណ ៩៥%។ អង្គប្រជុំឯកភាពគោរពស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលប្រសិទ្ធនាមផ្លូវនេះថា "**វិថីតេជោ**" និងស្ថាបនាវិមានព្រះសុគន្ធទ្រង់លើក្ងោក ស្ថិតនៅចំណុចប្រសព្វត្រីកោណ។

**៣. វឌ្ឍនភាពនៃការស្ថាបនាស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ស្ថានីយទី១ ស្ថានីយទី២ និងលើកទិសដៅស្ថាបនាស្ថានីយទី៣**

គ.អ.ធ.ក. បានចាត់ចែងរៀបចំស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន ២ ទីតាំង រួមមាន ទីតាំងទី ១ ស្ថិតនៅក្រោយសណ្ឋាគារ SUNSHINE BAY ឆ្នេរឯករាជ្យ មានសមត្ថភាពធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ ៥ ២០០ ម៉ែត្រគូបក្នុងមួយថ្ងៃ និងទីតាំងទី ២ នៅក្បែរសណ្ឋាគារសុខា មានសមត្ថភាពធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ ៧ ២០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលគុណភាពទឹកក្រោយការធ្វើប្រព្រឹត្តកម្មអាចបង្ហូរចូលសមុទ្របាន។ បច្ចុប្បន្ន ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី ១ សម្រេចលទ្ធផលបាន ៩៨% និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី២ សម្រេចលទ្ធផលបាន ១០០%។

គ.អ.ធ.ក. បាននិងកំពុងត្រៀមស្ថាបនាស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី៣ ដែលមានសមត្ថភាពធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងបរិមាណ ២០ ០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ស្ថិតនៅភូមិ ៤ សង្កាត់លេខ ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ត្រង់ចំណុចជាប់ស្ពានពយអូរឈើទាល។

**៤. គម្រោងប្លង់អភិវឌ្ឍរមណីយដ្ឋានឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប**

គ.អ.ធ.ក. គាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដែលមានប្រវែង ២ ៧០០ ម៉ែត្រ ក្នុងនោះមានឆ្នេរខ្សាច់កម្សាន្តសាធារណៈតាមបណ្តោយឆ្នេរសមុទ្រមានទទឹងយ៉ាងតិចប្រវែង ៣០ (សាមសិប) ម៉ែត្រ និងសួនច្បារសាធារណៈ និងដាំដើមឈើនៅលើដីចំណីឆ្នេរសមុទ្រមានទទឹងប្រវែង ៥០ (ហាសិប) ម៉ែត្រ ក្រោមទម្រង់នៃកិច្ចសហការអភិវឌ្ឍន៍រវាងរដ្ឋនិងឯកជនក្នុងគោលដៅកែលម្អនិងបង្កើតឆ្នេរខ្សាច់កម្សាន្តសាធារណៈ លម្អសាធារណៈ និងផ្ទៃបៃតងសម្រាប់សាធារណជននិងទេសចរ។/

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១